ក្រសួងអប់រំ យុវជន និង កីឡា

៚៚៚៚

# កំរងលំហាត់អំនានថ្នាក់ទី ៤
# នៃសាលារៀនបឋមសិក្សា

នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ

មហាវិទ្យាល័យគរុកោសល្យ

២០០០

## • និពន្ធ និង រៀបរៀងដោយ :

| | | | | | | |
|---|---|---|---|---|---|---|
| ១- លោក | សៅ ចាន់ | អធិការបឋមសិក្សា | | ១១-លោកស្រី | ឯម ហ៊ា | អធិការបឋមសិក្សា |
| ២- លោកស្រី | ទិត សារឿត | - - | | ១២-លោក | ជា ជឿន | - - |
| ៣- លោកស្រី | ប៊ុន សារ៉ន | - - | | ១៣-លោក | ប៉ែន គីមហ៊ារ | - - |
| ៤- លោកស្រី | ទេព្វ គីមហេង | - - | | ១៤-លោកស្រី | ម៉ក់ ពៅ | - - |
| ៥- លោក | ប៉ាច សារឿន | - - | | ១៥-លោក | យឹម ជឿង | - - |
| ៦- លោក | ម៉ុក សឿង | - - | | ១៦-លោកស្រី | យ៉ង់ ប៊ូលី | - - |
| ៧- លោកស្រី | ម៉េង ផាន់ណូរ៉ា | - - | | ១៧-លោកស្រី | ឡុង ម៉ាទីន | - - |
| ៨- លោក | យិន ប៊ុនហុង | - - | | ១៨-លោកស្រី | ប៊ូ ប៊ុននី | - - |
| ៩- លោក | អ៊ុក រ៉ាស៊ី | - - | | ១៩-លោក | អ៊ុក ដារ៉ា | - - |

## • កែសំរួល និង អានផ្ទៀងផ្ទាត់ដោយ :

| | | |
|---|---|---|
| ១- លោក | តាំង ឈុនឡេង | អតីតអនុប្រធានការិយាល័យបឋម និងមត្តេយ្យ នៅមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ |
| ២- លោក | នី រដ្ឋា | សាស្ត្រាចារ្យមហាវិទ្យាល័យគរុកោសល្យ |
| ៣- លោក | សម្បត្តិ វីរៈ | សាស្ត្រាចារ្យភាសាបារាំង |
| ៤- លោក | កុយ វ៉ាន់នី | ជំនួយការវគ្គបណ្តុះបណ្តាលគ្រូភាសាបារាំងនៅ មគស. |

## • ក្រោមការទទួលខុសត្រូវរបស់ :

លោកស្រី **Anne BARBARIT** អ្នកសំរបសំរួលវគ្គបណ្តុះបណ្តាលអធិការបឋមសិក្សា និងមធ្យមសិក្សា

នៅមហាវិទ្យាល័យគរុកោសល្យ

*　　*　　*

# មាតិការឿង


- លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ ទំព័រទី ៧ ........................................ ទំព័រទី ៧

- សេចក្តីថ្លែងអំនរគុណ ........................................ ទំព័រទី ៨

- អារម្ភកថា ........................................ ទំព័រទី ៩

- សេចក្តីណែនាំគរុកោសល្យទូទៅ ........................................ ទំព័រទី ១០

- ការបញ្ចូលលំហាត់អំនានស្ទាត់ទៅក្នុងការបង្រៀនអំនានថ្នាក់ទី៤ ........................................ ទំព័រទី ១៣


## ជំពូកទី ១


**មេរៀនទី ១ :** - មេសូត្រ "ការរស់នៅស្អាត"

លំហាត់ : រកពាក្យខុស ៤ ........................................ ទំព័រទី ១៥

- អំនានទី២ "ប្រយោជន៍នៃការអានសៀវភៅ"

លំហាត់ទី១ : ជ្រើសរើសចំលើយត្រូវមួយ ........................................ ទំព័រទី ១៧

លំហាត់ទី២ : ជ្រើសរើសចំលើយត្រូវ រឺ ខុស ........................................ ទំព័រទី ១៨

**មេរៀនទី ២ :** - អំនានទី១ "ប្រយោជន៍នៃការលេងកីឡា"

លំហាត់ទី១ : បំពេញចន្លោះ ........................................ ទំព័រទី ២០

លំហាត់ទី២ : រកពាក្យក្រៅក្រុម ........................................ ទំព័រទី ២១

- អំនានទី២ "ទិដ្ឋភាពល្បែងប្រទាំងកង់យឺត"

លំហាត់ទី១ : រកពាក្យដែលសរសេរខុសកន្លែង ........................................ ទំព័រទី ២៣

លំហាត់ទី២ : រកល្បះមួយដើម្បីបញ្ជាក់អត្ថបទ ........................................ ទំព័រទី ២៤

**មេរៀនទី ៣ :** - អំនានទី១ "តំលៃដ៏ពិសិដ្ឋរបស់មនុស្ស"

លំហាត់ទី១ : រកពាក្យខុស ៥ ........................................ ទំព័រទី ២៦

លំហាត់ទី២ : សំនួរពហុជ្រើសរើស ........................................ ទំព័រទី ២៧

- អំនានទី២ "កូនគោល និងគង្វាល"

លំហាត់ទី១ : រៀបល្បះឡើងវិញ ........................................ ទំព័រទី ២៩

លំហាត់ទី២ : រកពាក្យក្រៅក្រុម ..................................................... ទំព័រទី ៣០

**មេរៀនទី ៤ :** - អំនានទី១ "មិត្តស្និទ្ធស្នាល"

លំហាត់ទី១ : ភ្ជាប់សំនើពីរ ............................................................ ទំព័រទី ៣២

លំហាត់ទី២ : ជ្រើសរើសចំលើយត្រូវ រឺ ខុស ....................................... ទំព័រទី ៣៣

- អំនានទី២ "ផ្ទាំងគំនូរយើង"

លំហាត់ទី១ : រកពាក្យក្រៅក្រុម ..................................................... ទំព័រទី ៣៥

លំហាត់ទី២ : រកពាក្យក្រៅក្រុម ..................................................... ទំព័រទី ៣៦

## ជំពូកទី ២

**មេរៀនទី ១ :** - អំនានទី១ "សេចក្ដីសុខរបស់ប្រជាជន"

លំហាត់ទី១ : បំពេញចន្លោះ ........................................................... ទំព័រទី ៣៨

លំហាត់ទី២ : រកពាក្យក្រៅក្រុម ..................................................... ទំព័រទី ៣៩

- អំនានទី២ "វាសនានាងរដ្ឋា"

លំហាត់ទី១ : រៀបអត្ថបទឡើងវិញ ................................................ ទំព័រទី ៤១

លំហាត់ទី២ : សំនួរពហុជ្រើសរើស .................................................. ទំព័រទី ៤២

**មេរៀនទី ២ :** - អំនានទី១ "កន្លែងទេសចរណ៍ក្នុងប្រទេសកម្ពុជា"

លំហាត់ : រកពាក្យខុស ៥ ............................................................. ទំព័រទី ៤៤

- អំនានទី២ "ជ្រោះប៊ូស្រា"

លំហាត់ទី១ : បំពេញចន្លោះ ........................................................... ទំព័រទី ៤៦

លំហាត់ទី២ : ភ្ជាប់សំនើពីរ ............................................................ ទំព័រទី ៤៧

**មេរៀនទី ៣ :** - អំនានទី១ "សិប្បកម្មនៅប្រទេសកម្ពុជា"

លំហាត់ទី១ : សំនួរពហុជ្រើសរើស .................................................. ទំព័រទី ៤៩

លំហាត់ទី២ : រកពាក្យក្រៅក្រុម ...................................................... ទំព័រទី ៥០

- អំនានទី២ "សកម្មភាពកម្មករក្នុងរោងចក្រទឹកក្រូច"

លំហាត់ទី១ : រៀបអត្ថបទឡើងវិញ ................................................. ទំព័រទី ៥១

លំហាត់ទី២ : សំនួរពហុជ្រើសរើស .................................................. ទំព័រទី ៥២

## ជំពូកទី ៣

**មេរៀនទី ១ :** - អំនានទី១ "តូចតែសំបូរ"

លំហាត់ទី១ : រកពាក្យខុស ៥ ................................................ ទំព័រទី ៥៤

លំហាត់ទី២ : ស្រង់ពាក្យ ................................................ ទំព័រទី ៥៥

- អំនានទី២ "ការចិញ្ចឹមជីវិត"

លំហាត់ទី១ : រៀបល្បះឡើងវិញ ................................................ ទំព័រទី ៥៧

លំហាត់ទី២ : រកល្បះក្រៅក្រុម ................................................ ទំព័រទី ៥៨

**មេរៀនទី ២ :** - អំនានទី១ "ទន្លេមេគង្គ"

លំហាត់ទី១ : រកល្បះមួយដើម្បីបញ្ជាក់អត្ថបទ ................................................ ទំព័រទី ៦០

លំហាត់ទី២ : ភ្ជាប់ពាក្យក្នុងតារាង ................................................ ទំព័រទី ៦១

- អំនានទី២ "អ្នកតាទឹក អ្នកតាភ្នំ"

លំហាត់ទី១ : រកអត្ថបទពីរដាក់បញ្ចូលគ្នា ................................................ ទំព័រទី ៦៤

លំហាត់ទី២ : ភ្ជាប់សំនើពីរ ................................................ ទំព័រទី ៦៦

**មេរៀនទី ៣ :** - អំនានទី១ "ចំការកៅស៊ូ"

លំហាត់ទី១ : បំពេញចន្លោះ ................................................ ទំព័រទី ៦៧

លំហាត់ទី២ : រៀបល្បះឡើងវិញ ................................................ ទំព័រទី ៦៨

- អំនានទី២ "ផ្កេខ្ចិលធ្វើស្រែ"

លំហាត់ទី១ : រៀបអត្ថបទឡើងវិញ ................................................ ទំព័រទី ៧០

លំហាត់ទី២ : សំនួរពហុជ្រើសរើស ................................................ ទំព័រទី ៧១

**មេរៀនទី ៤ :** - អំនានទី១ "ជីវិតរស់នៅរបស់សត្វដំរី"

លំហាត់ទី១ : បំពេញចន្លោះ ................................................ ទំព័រទី ៧៣

លំហាត់ទី២ : ជ្រើសរើសចំលើយត្រូវ រឺ ខុស ................................................ ទំព័រទី ៧៤

- អំនានទី២ "រឿងមេអំបៅ និងដង្កូវ"

លំហាត់ទី១ : រកល្បះក្រៅក្រុម ................................................ ទំព័រទី ៧៦

លំហាត់ទី២ : ភ្ជាប់ពាក្យក្នុងតារាង ................................................ ទំព័រទី ៧៧

## ជំពូកទី ៤

**មេរៀនទី ១ :** - អំនានទី១ "រឿងបុណ្យភ្ជុំបិណ្ឌ"

លំហាត់ទី១ : រកពាក្យដែលសរសេរខុសកន្លែង ................................... ទំព័រទី ៧៩

លំហាត់ទី២ : រកល្បះក្រៅក្រុម ....................................................... ទំព័រទី ៨០

- អំនានទី២ "ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល"

លំហាត់ទី១ : រកពាក្យដែលសរសេរខុសកន្លែង ................................... ទំព័រទី ៨២

លំហាត់ទី២ : រកល្បះក្រៅក្រុម ....................................................... ទំព័រទី ៨៣

**មេរៀនទី ២ :** - អំនានទី១ "រឿងអណ្ដើក និងស្វា"

លំហាត់ទី១ : រកអត្ថបទពីរដាក់បញ្ចូលគ្នា ......................................... ទំព័រទី ៨៥

លំហាត់ទី២ : ជ្រើសរើសចំលើយត្រូវ រឺ ខុស ....................................... ទំព័រទី ៨៦

- មេសូត្រ "បុណ្យប្រពៃណីជាតិខ្មែរ"

លំហាត់ : សំនួរពហុជ្រើសរើស ........................................................ ទំព័រទី ៨៨

**មេរៀនទី ៣ :** - អំនានទី១ "រឿងរាជសីហ៍ និងកង្កែប"

លំហាត់ទី១ : បំពេញចន្លោះ ........................................................... ទំព័រទី ៨៩

លំហាត់ទី២ : ភ្ជាប់សំនើពីរ ............................................................. ទំព័រទី ៩០

- អំនានទី២ "រឿងភ្នំប្រុស ភ្នំស្រី"

លំហាត់ទី១ : ជ្រើសរើសសំនើត្រូវមួយ ............................................. ទំព័រទី ៩២

លំហាត់ទី២ : សំនួរពហុជ្រើសរើស ................................................... ទំព័រទី ៩៣

**មេរៀនទី ៤ :** - អំនានទី១ "សម្ដេចព្រះសង្ឃរាជ ជួន ណាត"

លំហាត់ទី១ : បំពេញចន្លោះ ........................................................... ទំព័រទី ៩៥

លំហាត់ទី២ : រៀបល្បះឡើងវិញ ...................................................... ទំព័រទី ៩៦

- អំនានទី២ "វចនានុក្រមខ្មែរ"

លំហាត់ទី១ : បំពេញចន្លោះ ........................................................... ទំព័រទី ៩៨

លំហាត់ទី២ : សំនួរពហុជ្រើសរើស ................................................... ទំព័រទី ៩៩

*  *  *

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * *

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ : ១៦៥៦ អយក.បវ

* * * * *

ភ្នំពេញ,ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០០

**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**ជំរាបមក**

**លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង**

**កម្មវត្ថុ :** ការអនុញ្ញាតអោយប្រើប្រាស់ឯកសារ "កំរងលំហាត់អំនានថ្នាក់ទី ៤ នៃសាលារៀនបឋមសិក្សា" នៅសាលារៀនបឋមសិក្សាក្នុងទូទាំងប្រទេស ។

**យោង :** លិខិតលេខ ១៤៧ គមស.សជ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបលោកប្រធានថា ក្រសួងបានអនុញ្ញាតអោយប្រើប្រាស់ "កំរងលំហាត់អំនានថ្នាក់ទី ៤ នៃសាលារៀនបឋមសិក្សា" ដែលគាត់តែងឡើងដោយក្រុមអធិការបឋមសិក្សា ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលកម្ពុជា សំរាប់ជាគុណប្រយោជន៍ដល់សាលាបឋមសិក្សាក្នុងទូទាំងប្រទេស ។

ឯកសារ "កំរងលំហាត់អំនានថ្នាក់ទី ៤ នៃសាលារៀនបឋមសិក្សា" នេះ ជាឯកសារពិគ្រោះ និងបំពេញបន្ថែមសំរាប់ប្រើប្រាស់អមជាមួយនឹងសៀវភៅភាសាថ្នាក់ទី ៤ សំរាប់គ្រូ ដែលក្រសួងបានអនុញ្ញាតអោយប្រើប្រាស់រួចហើយ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានបង្កលក្ខណៈ និងណែនាំការប្រើប្រាស់ឯកសារនេះ អោយបានលទ្ធផលល្អ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**ចំលងជូន :**

- សាលាខេត្ត-ក្រុង "*ដើម្បីសូមជ្រាបព័ត៌មាន*"
- អង្គភាពក្រុមឱវាទក្រសួង អយក. ដែលពាក់ព័ន្ធ "*ដើម្បីជ្រាបជាព័ត៌មាន* "
- កាលប្បវត្តិ
- ឯកសារ-នាយកដ្ឋាន ប.វ

# សូមថ្លែងអំណរគុណ

☆☆☆☆☆

## សូមថ្លែងអំណរគុណចំពោះ

★ សាស្ត្រាចារ្យឧទ្ទេស :

- លោក **Isdey COHEN**
- លោកស្រី **Annick MAUFFREY**

  សាស្ត្រាចារ្យនៅ I U F M Auteuil ទីក្រុង Paris ដែលបានអញ្ជើញមកបណ្តុះបណ្តាលអធិការបឋមសិក្សាស្តីពី "គរុកោសល្យនៃការបង្រៀនភាសា" នៅបឋមសិក្សា ។

★ សាស្ត្រាចារ្យឧទ្ទេស :

- មជ្ឈមណ្ឌលវប្បធម៌បារាំង **C C F** នៅភ្នំពេញ
- កម្មវិធី **PASEC II**
- សមាគម **អតីតសាស្ត្រាចារ្យ និងសិស្សនៃវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង** នៅទីក្រុងប៉ារីស ប្រទេសបារាំង
- សមាគម **GRIND'RI** នៃសាលាបារាំងនៅភ្នំពេញ **(Lycée français René DESCARTES)**
- លោកស្រី **ឆាយ អ៊ីវ៉ាន់** អាណិកជនខ្មែរនៅរដ្ឋ **Philadelphie** សហរដ្ឋអាមេរិក

- លោកស្រី **គៀត គិមហួរ** អាណិកជនខ្មែរនៅរដ្ឋ **Philadelphie** សហរដ្ឋអាមេរិក



# អារម្ភកថា

មុខវិជ្ជាអំនាន ជាមុខវិជ្ជាមួយសំខាន់បំផុតនៅសាលារៀនបឋមសិក្សា ។ ឆ្លងតាមការសិក្សានៃមុខវិជ្ជានេះ សិស្សអាចពង្រីកបានល្អនូវបញ្ញា ស្មារតីរបស់ខ្លួន ព្រមទាំងអាចមានមូលដ្ឋានចាំបាច់ សំរាប់ការសិក្សាមុខវិជ្ជាផ្សេងៗ ដទៃទៀត ។

ឆ្លើយតបទៅនឹងសារៈសំខាន់នៃមុខវិជ្ជាអំនាននេះ អធិការបឋមសិក្សាមួយក្រុម បានផ្តួចផ្តើមស្រាវជ្រាវ ចងក្រងឯកសារនេះឡើង ឈ្មោះហៅថា "កំរងលំហាត់អំនានថ្នាក់ទី ៣" ក្រោមការជួយឧបត្ថម្ភរបស់មហាវិទ្យាល័យ គរុកោសល្យ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ និង នាយកដ្ឋានស្រាវ- ជ្រាវគរុកោសល្យ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលកម្ពុជានិងក្នុងគោលបំនង ធ្វើអោយការបង្រៀន និងការរៀននៅសាលារៀនបឋមសិក្សាកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ។

កំរងលំហាត់អំនានថ្នាក់ទី ៣ នេះ គឺជាឯកសារអមជាមួយសៀវភៅភាសាខ្មែរថ្នាក់ទី ៣ របស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់គ្រូបង្រៀននៅបឋមសិក្សាប្រើប្រាស់ជាឯកសារពិគ្រោះ និងជាឯកសារស្រាវជ្រាវ ដែលអាចអោយគ្រូបង្រៀនជ្រើសរើសយកទៅអនុវត្តបាន ឬ អាចជួយគ្រូបង្រៀនក្នុងការពង្រីកសកម្មភាពអំនានតាមគោលវិធីសិស្សមជ្ឈមណ្ឌល "Child centered = Méthode centrée sur l'enfant" ។

សំរាប់មេរៀនអំនាននីមួយៗ សុទ្ធតែមានលំហាត់ពីរខុសៗគ្នា ដែលគ្រូបង្រៀនអាចយកជាគំរូ ឬ ជាគំនិត ដើម្បីតាក់តែងលំហាត់ប្លែកៗថែមទៀត ស្របទៅតាមវត្ថុបំនងរបស់មេរៀន និងទៅតាមសមត្ថភាពរបស់សិស្ស ប្រយោជន៏អោយសិស្សចេះត្រិះរិះពិចារណាដោយខ្លួនឯង និងចេះពិភាក្សាគ្នាតាមក្រុម ។

ឆ្លងតាមការអនុវត្តលំហាត់ទាំងនោះ សិស្សពិតជាអាចអភិវឌ្ឍខ្លួនឯងដោយផ្ទាល់ ពិសេស ចេះអានស្ងាត់ ដែលជាទំលាប់មួយយ៉ាងល្អ និងចាំបាច់បំផុតនៅក្នុងការរស់នៅ ។ អំនានស្ងាត់នេះ គួរតែត្រូវអនុវត្តតាំងពីថ្នាក់ទាបឡើងទៅ ទើបអាចមានប្រសិទ្ធភាព ព្រោះថា តទៅក្នុងជីវភាពប្រចាំថ្ងៃ ការប្រើអំនានស្ងាត់មានអាទិភាពច្រើនជាងអំនានលឺ ដូចជា ការអានស្លាកសញ្ញាផ្សេងៗ អានសារព័ត៌មាន ទស្សនាវដ្តី អានដើម្បីស្រាវជ្រាវ អានប្រលោមលោក ឬ រឿងរ៉ាវប្រវត្តិសាស្ត្រ អានឯកសារប្រលងជាដើម ។ ដូចនេះ អំនានស្ងាត់គឺជាសកម្មភាពតែមួយគត់ ដែលផ្សារភ្ជាប់ទៅនឹងការយល់អត្ថន័យពិតប្រាកដរបស់អត្ថបទ ហើយអាចជាគំនិតក្នុងការបង្កើតសំនេរ ។ រីឯអំនានលឺវិញ ជាអំនានមួយបែបមានប្រយោជន៏ណាស់ដែរ គឺអានសំរាប់អ្នកមិនចេះអក្សរស្តាប់ អានសំរាប់ជូនដំនឹងដល់អ្នក

ដែលគ្មានអត្ថបទនៅក្នុងដៃ ឬ អានសំរាប់ផ្សព្វផ្សាយព័ត៌មានផ្សេងៗ ។ ដើម្បីហ្វឹកហាត់បំនិននេះ យើងត្រូវត្រៀម សកម្មភាពពិសេសដោយឡែក ។ អោយសិស្សអានលឺ ដើម្បីអាចវាយតំលៃ និងកែលំអ : ការបន្លឺសំលេងអោយ ត្រូវតាមតួអក្សរ ការលើកដាក់សំលេងទៅតាមប្រភេទផ្សេងៗនៃអត្ថបទ ការគោរពសញ្ញាសំព័ន្ធ ។ល។

ដូចនេះ យើងអាចសន្និដ្ឋានបានថា អំនានទាំងពីរបែប មិនអាចចោលមួយណាបានឡើយ គឺចាំបាច់ត្រូវធ្វើ សកម្មភាពអោយបានសមស្របទៅនឹងតួនាទីរបស់អំនានទាំងពីរ ដើម្បីអភិវឌ្ឍបំនិនដោយឡែករបស់សិស្ស និង ដើម្បីធ្វើអោយការរៀន និងការបង្រៀនអំនានប្រព្រឹត្តទៅបានលទ្ធផលល្អ ។

ភ្នំពេញ,ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨

គណៈកម្មការនិពន្ធ និង រៀបរៀង

## ការបញ្ចូលលំហាត់អំនានស្ងាត់នៅក្នុងការបង្រៀនអំនានថ្នាក់ទី ៤

* * * * * *

| វិធីបង្រៀនអំនានថ្នាក់ទី ៤ ដែលមាននៅក្នុងសៀវភៅរបស់ ក្រសួងអប់រំ យុវជន និង កីឡា | | សំនើវិធីបង្រៀនអំនានដែល មានបញ្ចូលលំហាត់អំនានស្ងាត់ | |
|---|---|---|---|
| **ម៉ោងទី ១** | | | |
| • **រំលឹកមេរៀនចាស់**<br>• **សេចក្តីផ្តើម**<br><br><br><br>• **អំនានស្ងាត់លើកទី ១**<br><br><br><br><br>• **ការពន្យល់ពាក្យពិបាក** | ២-៧ នាទី<br>៣-៥ នាទី<br><br><br><br><br>២៥-២៨ នាទី | ២-៧ នាទី<br><br><br><br>១០-១៥ នាទី<br><br><br><br>១០-១៥ នាទី | • **រំលឹកមេរៀនចាស់**<br>• **លំហាត់អំនានស្ងាត់ទី ១** អាច ■<br>- ធ្វើអោយសិស្សជួបនឹងបញ្ហាដោយខ្លួនឯងផ្ទាល់<br>- ធ្វើអោយសិស្សចង់អាន និងមានទំលាប់ពិចារណា ដោះស្រាយបញ្ហា<br>- ធ្វើអោយសិស្ស **ចូលរួមវិភាគស្ងាត់ៗ** ទៅក្នុងអំនានពិតប្រាកដនៃអត្ថបទ<br>• **អំនានស្ងាត់ និង ការពន្យល់ពាក្យពិបាក** |
| សរុបពេល : | ៤០ នាទី | ៤០ នាទី | |
| **ម៉ោងទី ២** | | | |
| • **អំនានស្ងាត់លើកទី ២**<br>• **សំនួរលើអត្ថបទ** | ៨-១០ នាទី | ១០-១៥ នាទី | • **លំហាត់អំនានស្ងាត់ទី ២** អាចធ្វើអោយសិស្សយល់ដឹងដោយខ្លួនឯងកាន់តែ**ភីនជាលំដាប់** និង **យ៉ាងសកម្ម** ទៅលើខ្លឹមសារនៃ |

| | | | |
|---|---|---|---|
| • អំនានលឺ | ៥-១០ នាទី | ៣-៥ នាទី | អត្ថបទដែលបានអានម្តងរួចហើយ ។<br>• អំនានលឺ |
| • ការពង្រឹងចំណេះដឹង | ៥-៨ នាទី | ៥-៨ នាទី | • ការពង្រឹងចំណេះដឹង |
| • វាយតម្លៃ | ១០-១២ នាទី | ១០-១២ នាទី | • វាយតម្លៃ |
| សរុបពេល : | ៤០ នាទី | ៤០ នាទី | |

# ជំពូកទី ១

## មេរៀនទី ១

**មេសូត្រ** (អំនានទី១) — **វិជ្ជាជាសម្បត្តិ** — ស.ស ទំព័រទី ៤ ស.គ.ទំព័រទី ៦

**លំហាត់**

ហៃសាធុជនទាំងអស់គ្នា ចំនេះវិជ្ជាជាសម្មាយ
មានគុណវិសេសធំទូលាយ គួរយើងវេចស្ពាយកុំខ្លាចទន់ ។
មិនលំបាកទុក្ខស្រនុកលាក់ ជាជាងមាសប្រាក់សព្វទ្រព្យធន
មិនខ្លាចចោរលួច រឺ ចោរប្លន់ ទៅគ្រប់តំបន់គ្រាន់ជាស្បៀង ។
ឥតកណ្តៀរកោរកណ្តុរកាត់ បាយណាស់មិនបាត់មិនមានល្បៀង
ប្រើច្រើនកើតច្រើនចំរើនទៀង ពិបច្ចុប្បន្នរាងទៅអនាគត ។

ចូរអានអត្ថបទខាលើនេះដោយប្រុងប្រយ័ត្ន រួចរកពាក្យខុស ៤ ដែលមានក្នុងអត្ថបទនេះ។ សរសេរពាក្យ ទាំងនោះក្នុងសៀវភៅរបស់អ្នក រួចធ្វើកំនែផង ។

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅសិស្សទំព័រទី ៤ ទេ ព្រោះថា បើសិស្សបានអានអត្ថបទរួចហើយ លំហាត់នេះនឹងគ្មានន័យអ្វីទាំងអស់ ។

១- ចំលងលំហាត់ដាក់លើក្តារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ។

- ឱ្យសិស្សម្នាក់ឡើងមកគូសបន្ទាត់ពីក្រោមពាក្យខុសទី១ និងធ្វើអំណះអំណាងចំពោះចម្លើយរបស់ខ្លួន ព្រមទាំងធ្វើកំណែពាក្យនោះផង ។
- ឱ្យសិស្សឯទៀតកែកំហុសរៀងៗខ្លួនក្នុងសៀវភៅរបស់គេ ។
- ធ្វើបែបនេះរហូតដល់អស់ពាក្យខុស ។

<u>ចម្លើយ</u> :

| ពាក្យខុស | | ពាក្យត្រូវ |
|---|---|---|
| ទន់ | → | ធ្ងន់ |
| ទុក្ខ | → | ទុក |
| បាយ | → | ចាយ |
| រាង | → | រៀង |

*

*   *

## ជំពូកទី ១

### មេរៀនទី ១

អំណានទី២

**ប្រយោជន៍នៃអំណានសៀវភៅ**

ស.ស ទំព័រទី ៦

ស.គ.ទំព័រទី ១៤

**លំហាត់ទី១**

ចូរអានកថាខណ្ឌខាងក្រោម ។ ជ្រើសរើសយកសំណើមួយដែលត្រឹមត្រូវពីបណ្ដាសំណើទាំង ៣ នេះ ។ សរសេរចម្លើយក្នុងសៀវភៅរបស់អ្នក ។

អំនានសៀវភៅមិនត្រឹមតែ ① (ប្រគល់ / ឧបត្ថម្ភ / ផ្ដល់) ការយល់ដឹងដល់អ្នកប៉ុននោះទេថែមទាំងផ្ដល់ការសប្បាយ

រីករាយដល់អ្នកទៀត ព្រោះអ្នក ② (បានឃើញ / បានទទួល / បានគួរ) រូបភាពល្អៗ ប្លែកៗជាច្រើននៅក្នុងសៀវភៅ ។

ម៉្យាងទៀតនៅ ③ (ពេលអាន / ពេលបើក / ពេលឃើញ) សៀវភៅ អ្នកហាក់ដូចជាបាន ④ (ធ្វើការ / ធ្វើដំណើរ / ធ្វើអ្វី) ទៅដល់

កន្លែងដែលអ្នកនិពន្ធបាន ⑤ (រៀបចំ / រៀបរាប់ / ) នៅក្នុងអត្ថបទនោះ ។

| រៀបរយ |
|---|

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅសិស្សទំព័រទី ៦ ទេ។

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ។

- ឱ្យសិស្សម្នាក់ឡើងគូសចោលសំនើពីរទៀតដែលមិនសមស្របក្នុងឃ្លាទី១ ព្រមទាំងឱ្យធ្វើអំណះអំណាងចំពោះចម្លើយរបស់ខ្លួន ។
- ឱ្យសិស្សម្នាក់ទៀតអានឃ្លាដែលកែរួចហើយឡើងវិញ ។
- ធ្វើបែបនេះចំពោះឃ្លាះដទៃៗទៀត ។

ចម្លើយ :

១- ផ្ដល់ ២- បានឃើញ ៣- ពេលអាន

៤- ធ្វើដំនើរ ៥- រៀបរាប់

**លំហាត់ទី២**

តារាងខាងក្រោមមានអំណះអំណាងត្រូវផង ខុសផង ។

| | ខុស ឬ ត្រូវ | |
|---|---|---|
| ១ | | អំនានទាំឱ្យយើងហាក់ដូចជាបានធ្វើដំនើរ ។ |
| ២ | | អំនាននាំឱ្យយើងបានឃើញផ្ទាល់ផ្នែកនូវទេសភាពប្លែកៗ ។ |
| ៣ | | អំនាននាំឱ្យយើងបានសប្បាយរីករាយ ។ |
| ៤ | | អំនាននាំឱ្យយើងស្គាល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងប្រទេសមួយ ។ |
| ៥ | | អំនាននាំឱ្យយើងបានជួបនឹងមនុស្សថ្មី ។ |
| ៦ | | អំនាននាំឱ្យយើងបាត់អផ្សុក ។ |

| | | |
|---|---|---|
| ៦ | | អំនាននាំឱ្យយើងបាត់អផ្សុក ។ |

ចូរសរសេរពាក្យ "ខុស" ឬ "ត្រូវ" លើក្ដារឆ្នួនរបស់អ្នកតាមគំរូខាងក្រោម :

| | ខុស ឬ ត្រូវ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |
| ៥ | |
| ៦ | |

## លំនាំនៃការបង្រៀន

**ប្រយ័ត្ន !** ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅសិស្សទំព័រទី ៦ ទេ។

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ។

- ឱ្យសិស្សម្នាក់ផ្ដល់ចម្លើយរបស់គេចំពោះល្បះទី១ ព្រមទាំងបញ្ជាក់ហេតុផល ដោយយកអត្ថបទមកផ្ទៀងផ្ទាត់ ។
- ធ្វើដូចគ្នាចំពោះល្បះផ្សេងៗទៀត ។

ចម្លើយ :

| | ខុស ឬ ត្រូវ |
|---|---|
| ១ | ត្រូវ |
| ២ | ខុស |

| | |
|---|---|
| ៣ | ត្រូវ |
| ៤ | ត្រូវ |
| ៥ | ខុស |
| ៦ | ត្រូវ |

*

*　*

## ជំពូកទី ១

### មេរៀនទី ២

អំណានទី១ **ប្រយោជន៍នៃការលេងកីឡា** ស.ស ទំព័រទី ១៤ ស.គ.ទំព័រទី ៣៦

**លំហាត់ទី១**

ចូរអានកថាខណ្ឌខាងក្រោមដោយស្ងៀមស្ងាត់ ។ រកពាក្យមកបំពេញចន្លោះ ។ សរសេរចម្លើយដាក់ក្នុងសៀវភៅរបស់អ្នកតាមគំរូខាងក្រោម :

១- ..................　　៤- ..................

២- ..................　　៥- ..................

៣- ..................　　៦- ..................

ប្រយោជន៍នៃការលេង① _____

ការលេង ② _____ នាំឱ្យមនុស្សមានសុខភាពល្អ មានសាមគ្គីភាព មានស្មារតីក្រុម មានមោទនភាព ចំពោះខ្លួន ក្រុមខ្លួន និងសង្គមជាតិ ។ អ្នកលេង ③ _____ តែមានសាច់ឈាមស្រស់ថ្លា គ្មានជំងឺផ្សេងៗមក④ _____ ខ្លួនឡើយ ។ ក្រៅពីនេះ អ្នកលេង ⑤_____ ច្រើនបរិភោគបាយបានឆ្ងាញ់ ហើយសំរាន្តបានលក់ស្រួល

○

ដោយមិនចាំបាច់ប្រើថ្នាំជំនួយ ។ ជាងនេះទៅទៀត អ្នកលេង ៦ _______ ជាមនុស្សមានមិត្តច្រើន ចេះជួយគ្នា និងមានអធ្យាស្រ័យល្អជាមួយគ្នា ។

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅសិស្សទំព័រទី ១៤ទេ។

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយឱ្យសិស្ស ២ ឬ ៣ នាក់ឡើងទៅសរសេរបំពេញចន្លោះកថាខណ្ឌដែលមាននៅលើក្ដារខៀន ព្រមទាំងធ្វើអំណះអំណាងចំពោះចម្លើយរបស់ខ្លួនផង ។

ចម្លើយ :

| | | |
|---|---|---|
| ១- កីឡា | ២- កីឡា | ៣- កីឡា |
| ៤- បៀតបៀន ឬ យាយី ឬ ព្យាបាទ | ៥- កីឡា | ៦- កីឡា |

**លំហាត់ទី២**

កថាខណ្ឌខាងក្រោមមានកន្សោមពាក្យ ៣ ដែលសរសេរលើស ។

ចូរអានកថាខណ្ឌនេះ រួចរកឱ្យឃើញកន្សោមពាក្យលើសទាំងនោះ ។ សរសេរចម្លើយដាក់លើក្ដារឆ្នួន ។

ពយកគេចេះលើកទឹកចិត្តគ្នា និងចេះចែករំលែករង្វាន់ដែលក្រុមខ្លួនទទួលបានដល់សមាជិកម្នាក់ៗ និងវិនៃតានៅក្នុងក្រុម ។ ពិសេសជាងនេះទៅទៀត អ្នកលេងកីឡាតែងទទួលបានការកោតសរសើរពីសំណាក់គ្រួសារ មហាជន បក្សាបក្សី និងសហគមន៍ ។ អ្នកលេងកីឡាតែងតែចង់កសាងកេរ្តិ៍ឈ្មោះល្អរបស់ខ្លួន តាមរយៈការលេង បានត្រឹមត្រូវ និងស្អាត់ជមនាញ ហើយព្រមទទួលយកលទ្ធផលឈ្នះ ឬ ចាញ់ ដោយជឿជាក់ស្មោះស្ម័គ្រ និងថ្លៃថ្នូរ ជាទីបំផុត ភាពញញឹមរបស់គេ ។

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** អំនានស្ងាត់លើកទី១ បានធ្វើរួចហើយនៅម៉ោងទី១ ។ ពេលធ្វើលំហាត់នៅម៉ោងទី២ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ១៤ ឡើងវិញម្ដងទៀតឡើយ ។

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយឱ្យសិស្សម្នាក់ឡើងមកគូសចោលពាក្យដែលលើស រួចឱ្យសិស្សនោះអះអាងថា ហេតុអ្វីបានជាថាកន្សោមពាក្យនោះលើស ? ធ្វើដូចគ្នាចំពោះកន្សោមពាក្យផ្សេងៗទៀត ។

<u>ចម្លើយ</u> :

- និងវីនតា - បក្សាបក្សី - ភាពញញឹមរបស់គេ

*

* *

## ជំពូកទី ១

### មេរៀនទី ២

**អំនានទី២** **ទិដ្ឋភាពល្បែងប្រណាំងកង់យឺត** ស.ស ទំព័រទី ១៨ ស.គ.ទំព័រទី ៤៦

**<u>លំហាត់ទី១</u>**

កថាខណ្ឌខាងក្រោម មានពាក្យ និងកន្សោមពាក្យខ្លះសរសេរមិនត្រឹមត្រូវតាមកន្លែង ។ ចូរចម្លងកថាខណ្ឌនេះឡើងវិញដាក់ក្នុងសៀវភៅរបស់អ្នក ដោយដាកពាក្យទាំងនោះឱ្យបានត្រឹមត្រូវតាម កន្លែងដើមរបស់វា និងគូសបន្ទាត់ពីក្រោមផង ។

**ទិដ្ឋភាពល្បែងប្រណាំងកង់យឺត**

ការប្រណាំងកង់យឺតជាមួយប្រភេទល្បែងដែលសិស្សានុសិស្សលេងចូលចិត្ត និងទស្សនានៅពេលពិធីបុណ្យផ្សេងៗមានក្នុងសាលារៀន ។ រាល់ឆ្នាំក្នុងបើកបវេសនកាល ឱកាសនៅសាលាមួយចំនួន គេតែងរៀបចំឱ្យសិស្សកម្មវិធីសំខាន់កំសាន្តសប្បាយ ។

## លំនាំនៃការបង្រៀន

**ប្រយ័ត្ន !** ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅសិស្សទំព័រទី ១៨ ទេ។

១- ចំលងលំហាត់ដាក់លើក្តារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្តារខៀន ដោយឱ្យសិស្សរកអំណះអំណាងចំពោះចម្លើយរបស់គេដែលបានជ្រើសរើស ។

ចម្លើយ :

### ទិដ្ឋភាពល្បែងប្រណាំងកង់យឺត

ការប្រណាំងកង់យឺត ជាល្បែងមួយប្រភេទដែលសិស្សានុសិស្សចូលចិត្តលេង និងទស្សនានៅពេលមានពិធីបុណ្យផ្សេងៗក្នុងសាលារៀន ។ រាល់ឆ្នាំក្នុងឱកាសបើកបវេសនកាល នៅសាលាមួយចំនួនគេតែងរៀបចំកម្មវិធីសំ-
ខាន់ឱ្យសិស្សកំសាន្តសប្បាយ ។

## លំហាត់ទី២

ចូរអានកថាខណ្ឌខាងក្រោម :

ការប្រណាំងកង់យឺត ជាល្បែងមួយប្រភេទដែលសិស្សានុសិស្សចូលចិត្តលេង និងទស្សនានៅពេលមានពិធីបុណ្យផ្សេងៗក្នុងសាលារៀន ។ ពេលមានកម្មវិធីប្រណាំងកង់ម្តងៗ សិស្សម្នាក់ៗមានទឹកមុខរីករាយ ។ នេះបញ្ជាក់ថា ពួកគេពេញចិត្តខ្លាំងណាស់នឹងល្បែងប្រភេទនេះ ។ ក្នុងពេលប្រណាំង អ្នកប្រកួតម្នាក់ៗខិតខំបញ្ចេញភាពស្វាហាប់ និងបំណិនប្រសប់របស់ខ្លួនយ៉ាងពេញទំហឹង ។

អ្នកទស្សនាខ្លះស្រែកដាក់តឿនមិត្តភក្តិខ្លួនឱ្យខំប្រឹងប្រែងដើម្បីដណ្តើមយកជោគជ័យ ។ ចំណែកអ្នកទស្សនាខ្លះទៀត រីសេកហ៊ោសប្បាយពេលឃើញកង់ណាមួយដួល ។ សរុបមក ..........................................

..........................................................................................................................

..........................................................................................................................។

ដើម្បីបញ្ចប់រឿងនេះ ចូរជ្រើសរើសសំណើណាមួយដែលសមហើយល្អជាងគេក្នុងបណ្តាសំណើទាំង ៣

ខាងក្រោម ។ សរសេរតែលេខនៃសំណើនោះដាក់លើក្ដារឆ្នួនរបស់អ្នក ។

| | |
|---|---|
| ១ | ល្បែងប្រណាំងកង់យឺតជាល្បែងមួយប្រភេទដែលហត់នឿយណាស់ ។ |
| ២ | ល្បែងប្រណាំងកង់យឺតជាល្បែងមួយប្រភេទដែលធ្វើឱ្យកុមារមានអារម្មណ៍រីករាយសប្បាយ និងមានសេចក្ដីក្លាហាន ។ |
| ៣ | ល្បែងប្រណាំងកង់យឺតជាល្បែងមួយប្រភេទដែលមានគ្រោះថ្នាក់ជាទីបំផុត ។ |

**លំនាំនៃការបង្រៀន**

១- ចម្លងលំហាត់ទាំងមូលដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ឬ បើមានលទ្ធភាពគួរសរសេរសំណើទាំង ៣ លើផ្ទាំងក្រដាសដាច់ពីគ្នា ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។

មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយឱ្យសិស្សបញ្ជាក់ពីហេតុផលនៃការជ្រើសរើសចម្លើយរបស់គេផង ។

ចម្លើយ : សំណើលេខ ២

*

* *

## ជំពូកទី ១

### មេរៀនទី ៣

អំណានទី១ **តម្លៃដ៏ពិសិដ្ឋរបស់មនុស្ស** ស.ស ទំព័រទី ២៥

ស.គ.ទំព័រទី ៥៧

**លំហាត់ទី១**

ចូរអានកថាខណ្ឌខាងក្រោម រួចរកឱ្យឃើញពាក្យខុស ៥ ។

សរសេរពាក្យខុសទាំងនោះដាក់ក្នុងសៀវភៅរបស់អ្នក ព្រមទាំងធ្វើកំណែផង ។

**តម្លៃដ៏ពិសិដ្ឋរបស់មនុស្ស**

វិន័យ នឹងការសិក្សាមានតម្លៃខ្ពង់ខ្ពស់បំផុតសម្រាប់មនុស្ស ។ ការសិក្សាផ្ដល់ចំណេះវិជ្ជាដល់មនុស្ស ។

ចំណេះវិជ្ជាជួយមនុស្សឱ្យចេះគតិពិចារណាបានត្រឹមត្រូវ និងប្រកបរបរចិញ្ចឹមជីវិតបានស្រួល ។ មានតែប៉ុណ្ណោះ ចំណេះដឹងញ៉ាំងគេឱ្យក្លាយជាអ្នកប្រាជ្ញបណ្ឌិត ។ ដោយឡែកវិន័យអប់រំមនុស្សឱ្យមានសីលធម៌ល្អ ស្គាល់ខុសត្រូវ ល្អ អាក្រក់ និងមានអត្តចរិកដែផ្ទូរ ។ វិន័យជួយមនុស្សឱ្យគ្រប់គ្រងខ្លួនឯងបាន និងចេះវិនិច្ឆ័យថា អំពើណានាំខ្លួនឱ្យមានកិត្តិស័ព្ទ និងគួរជាទីចូលចិត្តរបស់នាក់ផងទាំងពួង ។

<u>**លំនាំនៃការបង្រៀន**</u>

**<u>ប្រយ័ត្ន</u>** ! មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី២៥ ពេលធ្វើលំហាត់ឡើយ ។

១- ចម្លងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ឱ្យសិស្សដូរសៀវភៅគ្នាកែ ។

៦- ធ្វើកំណែរួមនៅលើក្ដារខៀន ។

- ឱ្យសិស្សឡើងមកបង្ហាញពាក្យខុស រួចឱ្យគូសពាក្យនោះចោល ព្រមទាំងឱ្យធ្វើកំណែផង ។
- ធ្វើរបៀបនេះរហូតដល់ចប់ ។
- ឱ្យសិស្សពីរ ឬ បីនាក់អានកថាខណ្ឌដែលកែរួចនោះឡើងវិញ ។

**<u>ប្រយ័ត្ន</u>** ! នៅពេលធ្វើលំហាត់ទី១នេះរួច មិនបាច់ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ២៥ លឺៗទេ ព្រោះថា បើសិស្សអានលឺៗនោះ លំហាត់ទី២នឹងបាត់បង់សារប្រយោជន៍គរុកោសល្យរបស់វា ។

<u>ចម្លើយ</u> :

| <u>ពាក្យខុស</u> | | <u>ពាក្យត្រូវ</u> |
|---|---|---|
| នឹង | → | និង |
| គតិ | → | គិត |
| មាន | → | មិន |
| ដៃផ្ទូរ | → | ថ្លៃថ្នូរ |
| នាក់ | → | អ្នក |

**លំហាត់ទី២**

| |
|---|
| ល្បះពីរខាងក្រោមមានសំណើបី ដែលជាអត្ថន័យរបស់ល្បះនីមួយៗ ។<br>ចូរជ្រើសរើសសំណើណាមួយដែល មានអត្ថន័យត្រឹមត្រូវជាងគេសម្រាប់ល្បះនីមួយៗ ។<br>សរសេរលេខសំណើនោះដាក់លើក្ដារឆ្នួនរបស់អ្នក ។<br>ក- មនុស្សអវិជ្ជាប្រៀបដូចជាមនុស្សងងឹតភ្នែកមានន័យថា :<br>១- មនុស្សអវិជ្ជាជាមនុស្សដែលមើលមិនឃើញ ។<br>២- មនុស្សអវិជ្ជាជាមនុស្សដែលគ្មានចំណេះវិជ្ជា ។<br>៣- មនុស្សអវិជ្ជាជាមនុស្សដែលត្រូវតែពាក់វ៉ែនតា ។<br>ខ- មនុស្សខ្វះវិន័យ ឬ អសីលធម៌ ប្រៀបដូចជាសត្វសាហាវ មានន័យថា :<br>១- មនុស្សខ្វះវិន័យ ឬ អសីលធម៌ ជាមនុស្សដែលមិនគោរពច្បាប់ និងព្រហើនកោងកាច ។<br>២- មនុស្សខ្វះវិន័យ ឬ អសីលធម៌ ជាមនុស្សដែលតស៊ូខិតខំរកស៊ីចិញ្ចឹមជីវិត ។<br>៣- មនុស្សខ្វះវិន័យ ឬ អសីលធម៌ ជាមនុស្សដែលមិនចេះអានអក្សរ ។ |

**លំនាំនៃការបង្រៀន**

១- ចម្លងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៥- ធ្វើកំណែរួមនៅលើក្ដារខៀន ។

បើសិស្សឆ្លើយខុស គ្រូត្រូវឱ្យសិស្សនោះបញ្ជាក់ពីហេតុផលនៃការជ្រើសរើសចម្លើយរបស់គេ រួចទើបពន្យល់ ជាខាងក្រោយ ។

<u>ចម្លើយ</u> :

ក - ២

ខ - ១

លំហាត់ទី១

*
* *

# ជំពូកទី ១

## មេរៀនទី ៣

អំណានទី២

**កូនគោ និង គង្វាល**

ស.ស ទំព័រទី ២៨

ស.គ.ទំព័រទី ៦៦

**លំហាត់ទី១**

កថាខណ្ឌខាងក្រោមមានបីល្បះ។ សេចក្ដីបញ្ចប់របស់ល្បះនីមួយៗដែលគួរសបន្ទាត់ពីក្រោម

ត្រូវប្តូរទីតាំង ប៉ុន្តែផ្នែកខាងដើមនៃល្បះទាំងនោះនៅរក្សាទុកដដែល ។

ចូរសរសេរល្បះទាំងនោះឡើងវិញដាក់ក្នុងសៀវភៅរបស់អ្នក ដើម្បីធ្វើឱ្យកថាខណ្ឌនេះមានន័យសមស្រប ។

បុរសគង្វាលគោលម្នាក់ នាំគោមួយហ្វូងធំ សម្រាប់គោទាំងឡាយ ។

នៅទីនោះមានវាលស្មៅខៀវស្រងាត់ ទៅក្បែរជើងភ្នំ ។

វាលស្មៅនោះជាកន្លែងមួយដ៏ត្រកាល និងទឹកអូរថ្លាយង់ ។

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ២៨ ឡើយ ។

១- ចម្លងលំហាត់ដាក់លើក្តារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ត្រូវបញ្ជាក់ប្រាប់សិស្សថា មិនមែនត្រឹមតែធ្វើឱ្យល្បះមានន័យទេ តែត្រូវធ្វើឱ្យកថាខណ្ឌទាំងមូលមានន័យផង ។

៥- ឱ្យសិស្សធ្វើលំហាត់ជាដៃគូ (ពីរៗនាក់) ដោយឱ្យចម្លងកថាខណ្ឌដែលត្រឹមត្រូវដាក់ក្នុងសៀវភៅ ។ បើសិស្សមិនទាន់យល់សំណួមពររបស់លំហាត់ទេ គ្រូត្រូវឱ្យសិស្សផ្អាកការងារសិន រួចរកឧទាហរណ៍ផ្សេងៗមកពន្យល់ ។ ការបើសិស្សយល់សំណួមពររបស់លំហាត់បានច្បាស់ហើយ សឹមឱ្យសិស្សបន្តការងារតទៅទៀត ។

៦- ធ្វើកំណែរួមនៅលើក្តារខៀន ដោយឱ្យសិស្ស ២ ឬ ៣ នាក់ អានកថាខណ្ឌដែលគេបានសរសេររួច (អំណានលឺ) គ្រូ និងសិស្សដទៃទៀតស្តាប់ ហើយពិចារណា : តើកថាខណ្ឌទាំងមូលមានន័យហើយ ឬ នៅ ? បើពិនិត្យឃើញ ថា ក្នុងកថាខណ្ឌនេះមានល្បះពីរមានន័យហើយ ឯល្បះមួយទៀតគ្មានន័យ កថាខណ្ឌនេះមិនអាចទទួលយកបាន ឡើយ ។

ចម្លើយ :

បុរសគង្វាលគោលម្នាក់ នាំគោមួយហ្វូងធំទៅក្បែរជើងភ្នំ ។

នៅទីនោះមានវាលស្មៅខៀវស្រងាត់ និងទឹកអូរថ្លាយង់ ។

វាលស្មៅនោះជាកន្លែងមួយដ៏ត្រកាល សម្រាប់គោទាំងឡាយ ។

**លំហាត់ទី២**

អ្នកបានអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ២៨ រួចហើយ ។ ក្នុងបញ្ជីឈ្មោះតួអង្គ និងទីកន្លែង ខាងក្រោម ចូរស្រង់តែតួអង្គ និងទីកន្លែងណាដែលគ្មាននៅក្នុងរឿងនេះ សរសេរចម្លើយដាក់លើក្តារឆ្នួនរបស់អ្នក ។

| | |
|---|---|
| ១- គង្វាលគោ | ៦- ដងស្ទឹង |
| ២- ក្បែរជើងភ្នំ | ៧- ខ្លា |
| ៣- កូនគោ | ៨- គោ |
| ៤- ចចក | ៩- អូរ |
| ៥- ព្រៃជ្រៅ | ១០- ចៀម |

**<u>លំនាំនៃការបង្រៀន</u>**

១- ចម្លងលំហាត់ដាក់លើក្តារខៀនឱ្យបានមុនម៉ោងបង្រៀន រួចបិទទុកសិន ។

២- ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ២៨ ដោយស្ងៀមស្ងាត់ ហើយប្រាប់សិស្សថា ត្រូវអាន ដោយប្រុងប្រយ័ត្ន ព្រោះពួកគេត្រូវធ្វើលំហាត់មួយ ។ ពេលធ្វើលំហាត់មិនឱ្យសិស្សអានអត្ថបទទៀតទេ ។

៣- ឱ្យសិស្សទាំងអស់បិទសៀវភៅ ។

៤- បង្ហាញលំហាត់ និងឱ្យសិស្សអានដោយស្ងៀមស្ងាត់ ។

៥- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"
ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៦- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៧- ធ្វើកំណែរួមនៅលើក្តារខៀន ដោយឱ្យសិស្សរកអំណះអំណាងមកបញ្ជាក់ចំពោះចម្លើយរបស់ខ្លួនផង ។

<u>ចម្លើយ</u> : ៤- ចចក ៦- ដងស្ទឹង ១០- ចៀម

*

* *

## ជំពូកទី ១

### មេរៀនទី ៤

**អំណានទី១**

| **មិត្តស្និទ្ធស្នាល** |
|---|

ស.ស ទំព័រទី ៣៧

ស.គ.ទំព័រទី ៧៨

**លំហាត់ទី១**

អ្នកបានអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ៣៧ រួចហើយ ។ ចូរភ្ជាប់សំដីនៃតួអង្គនីមួយៗទៅ នឹងឈ្មោះតួអង្គដែលបាននិយាយ ។ សរសេរតែលេខល្បះ និងឈ្មោះតួអង្គនៅលើក្តារឆ្នួនរបស់អ្នក ។

| | សំដីតួអង្គ | ឈ្មោះតួអង្គ |
|---|---|---|
| ១ | ខ្ញុំមានរបស់មួយធ្វើឱ្យឯងទាំងពីរឆ្ងល់ ។ | បងប្រុសសាត |
| ២ | ឯងជាអ្នកធ្វើមែន ឬ ទេ ? | ពិសី |
| ៣ | មែនហើយ ! បងប្រុសខ្ញុំបានបង្រៀនខ្ញុំ ។ | សាត |
| ៤ | តោះយើងឆាប់រៀនធ្វើទៅ ! | សុធី |

**លំនាំនៃការបង្រៀន**

១- ចម្លងលំហាត់ដាក់លើក្តារខៀនឱ្យបានមុនម៉ោងបង្រៀន រួចបិទទុកសិន ។

២- ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ៣៧ ដោយស្ងៀមស្ងាត់ រួចឱ្យបិទសៀវភៅទុក ។

៣- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៤- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៥- ឱ្យសិស្សដូរសៀវភៅគ្នាកែ ។

៦- ធ្វើកំណែរួមនៅលើក្តារខៀន ដោយសិស្សរកអំណះអំណាងមកបញ្ជាក់ចំពោះចម្លើយរបស់ខ្លួនផង ។

ចម្លើយ :

១-៣- → សាត

២- → សុធី

៤- → ពិសី

**លំហាត់ទី២**

ចូរគូសតារាងខាងក្រោមនេះដាក់លើក្តារឆ្នួនរបស់អ្នក ហើយសរសេរ "ត្រូវ" ឬ "ខុស" ក្រោយពីបានអាន ល្បះទាំង ៥ ខាងក្រោមរួច ។

| | ខុស ឬ ត្រូវ |
|---|---|
| ក | |
| ខ | |
| គ | |
| ឃ | |
| ង | |

| | | ត្រូវ ឬ ខុស |
|---|---|---|
| ក | ថ្ងៃអាទិត្យមួយ មិត្តទាំងបីនាក់បានជួបជុំគ្នានៅផ្ទះសាតដើម្បីបត់ក្រដាស ។ | |
| ខ | សាត ពិសី និង សុធី មិនមានទំនាក់ទំនងល្អនឹងគ្នាទេ ។ | |
| គ | សុធី និង ពិសី រៀនបត់ក្រដាសដោយធ្វើតាមសាត ។ | |
| ឃ | គេនាំគ្នាធ្វើសត្វចចាតអំពីក្រដាស ។ | |
| ង | ពិសីធ្វើចាបមិនបានសម្រេចទេ ។ | |

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។

មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ៣៧ ដោយស្ងៀមស្ងាត់ រួចឱ្យបិទសៀវភៅទុក ។

៥- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៦- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយឱ្យសិស្សផ្ដល់ចម្លើយ ព្រមទាំងរកអំណះអំណាងមកបញ្ជាក់ចំពោះចម្លើយរបស់ខ្លួនផង ។

<u>ចម្លើយ</u> :

| | ត្រូវ ឬ ខុស |
|---|---|
| ក | ខុស |
| ខ | ខុស |

| | |
|---|---|
| គ | ត្រូវ |
| ឃ | ខុស |
| ង | ខុស |

*

*        *

## ជំពូកទី ១

### មេរៀនទី ៤

អំណានទី២

**ផ្ទាំងគំនូរយើង**

ស.ស ទំព័រទី ៤១

**លំហាត់ទី១**

កថាខណ្ឌខាងក្រោមមានល្បះមួយលើស ហើយមានន័យមិនទាក់ទងទៅនឹងអត្ថបទនេះទេ ។ ចូររកល្បះនោះ និងសរសេរលេខរបស់វាដាក់លើក្ដារឆ្នួនរបស់អ្នក ។

①- មិត្តភក្ដិនៅថ្នាក់រៀនខ្ញុំ មានចំណូលចិត្តធ្វើការជាក្រុម ។②- ក្រុមនីមួយៗមានចំណូលចិត្តប្លែកៗពីគ្នា ។③- ក្រុមខ្លះចូលចិត្តប្រមូលរូបភាព រូបថតពីសារព័ត៌មាន ឬ ទស្សនាវដ្ដីយកមកកាត់ រួចយកមកបិទក្នុងសៀវភៅមួយ ដោយរៀបវាតាមប្រធានបទដោយឡែកៗ ។④- ថ្ងៃមួយ យើងសម្រេចចិត្តនាំគ្នាទៅលេងសមុទ្រ ។⑤- ក្រុមខ្លះចូលចិត្តសូនដីធ្វើរូបផ្សេងៗ ។⑥- ក្រៅពីការងារហត្ថកម្ម ពួកគេតែងជួយពន្យល់គ្នាទៅមកអំពីមេរៀន ឬ លំហាត់ផ្សេងៗដែលគ្រូដាក់ឱ្យធ្វើ ។

**លំនាំនៃការបង្រៀន**

**ប្រយ័ត្ន !** មិនអនុញ្ញាតឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ២៨ ឡើយ ។

១- ចម្លងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន រួចបិទទុកសិន ។

២- ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ៣៧ ដោយស្ងៀមស្ងាត់ រួចឱ្យបិទសៀវភៅទុក ។

៣- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៤- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។ មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៥- ឱ្យសិស្សដូរសៀវភៅគ្នាកែ ។

៦- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយសិស្សរកអំណះអំណាងមកបញ្ជាក់ចំពោះចម្លើយរបស់ខ្លួនផង ។

ចម្លើយ :

១-៣- → សាត

២- → សុធី

៤- → ពិសី

**លំហាត់ទី២**

ចូរគូសតារាងខាងក្រោមនេះដាក់លើក្ដារឆ្នួនរបស់អ្នក ហើយសរសេរ "ត្រូវ" ឬ "ខុស" ក្រោយពីបានអាន ល្បះទាំង ៥ ខាងក្រោមរួច ។

| | ខុស ឬ ត្រូវ |
|---|---|
| ក | |
| ខ | |
| គ | |
| ឃ | |
| ង | |

| | | ត្រូវ ឬ ខុស |
|---|---|---|
| ក | ថ្ងៃអាទិត្យមួយ មិត្តទាំងបីនាក់បានជួបជុំគ្នានៅផ្ទះសាតដើម្បីបត់ក្រដាស ។ | |
| ខ | សាត ពិសី និង សុធី មិនមានទំនាក់ទំនងល្អនឹងគ្នាទេ ។ | |
| គ | សុធី និង ពិសី រៀនបត់ក្រដាសដោយធ្វើតាមសាត ។ | |
| ឃ | គេនាំគ្នាធ្វើសត្វចចាតអំពីក្រដាស ។ | |
| ង | ពិសីធ្វើចាបមិនបានសម្រេចទេ ។ | |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនឱ្យបានមុនម៉ោងបង្រៀន ។

២- ឱ្យសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា : "តើក្នុងលំហាត់នេះគេឱ្យអ្នកធ្វើអ្វី ?"

ឱ្យសិស្សឆ្លើយមកវិញឱ្យបានច្រើននាក់ដោយផ្ទាល់របស់គេ មុននឹងឱ្យធ្វើលំហាត់ ។

មិនឱ្យសិស្សអានសំណួមពរ របស់លំហាត់ឡើងវិញឡើយ ។

៤- ឱ្យសិស្សអានអត្ថបទអំណានក្នុងសៀវភៅសិស្សទំព័រទី ៣៧ ដោយស្ងៀមស្ងាត់ រួចឱ្យបិទសៀវភៅទុក ។

៥- ទុកពេលឱ្យសិស្សធ្វើលំហាត់ ។

៦- ធ្វើកំណែរួមនៅលើក្ដារខៀន ដោយឱ្យសិស្សផ្ដល់ចម្លើយ ព្រមទាំងរកអំណះអំណាងមកបញ្ជាក់ចំពោះចម្លើយរបស់ខ្លួនផង ។

ចម្លើយ :

| | ត្រូវ ឬ ខុស |
|---|---|
| ក | ខុស |
| ខ | ខុស |

| | |
|---|---|
| គ | ត្រូវ |
| ឃ | ខុស |
| ង | ខុស |

*

*           *